## ឧបសម្ព័ន្ធទី ១ : ការចូលរៀនប្រកបដោយសមធម៌ : តារាងសកម្មភាពគោលនយោបាយតម្រង់ទិសវិស័យ ២០០៤_០៨

| វិសាលភាពគោលនយោបាយ និងយុទ្ធសាស្ត្រ | សកម្មភាព ( ដំណាច់ឆ្នាំ ២០០៤ ) | សកម្មភាព (ពាក់កណ្តាលឆ្នាំ ២០០៦ ) | សកម្មភាព (ដើមឆ្នាំ ២០០៨ ) |
|---|---|---|---|
| ក-កាត់បន្ថយចំណាយរបស់មាតាបិតាសិស្ស ចំពោះការអប់រំមូលដ្ឋាន | • ចេញប្រកាសលុបបំបាត់ការបង់វិភាគទានក្រៅផ្លូវការរបស់មាតាបិតាសិស្ស ពីថ្នាក់ទី១-៩<br>• កិច្ចព្រមព្រៀងរួមគ្នារវាង ក្រសួង អ.យ.ក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើផែនការរបស់ កសអ សំរាប់ថវិកាដំណើរការសាលាបឋម និងមធ្យមសិក្សា។ | • ដាក់អនុវត្តនូវបទបញ្ញត្តិ និងគោលការណ៍ណែនាំ សំរាប់ការគ្រប់គ្រង និងកិច្ចបញ្ជីការគណនេយ្យ ចំពោះការបង់វិភាគទាន របស់មាតាបិតាសិស្សជាផ្លូវការ<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្តធ្វើកិច្ចព្រមព្រៀងទៅលើការបែងចែកថវិកា កសអ សំរាប់ដំណើរការសាលារៀន។ | • សិក្សាពីផលប៉ះពាល់នៃអនុក្រឹត្យ និងបទបញ្ញត្តិ ដែលបានកែសំរួល ស្តីពីការធ្វើហិរញ្ញប្បទានដល់សាលារៀន ដែលរួមមានសកម្មភាពនានា លើបទពិសោធន៍ដែលទទួលបាន<br>• ពិនិត្យឡើងវិញនូវថវិការួមរបស់សាលាបឋម និងមធ្យមសិក្សា ដែលត្រូវចំណាយសំរាប់ឆ្នាំ ២០០៤-០៧។ |
| ខ-លើកកំពស់អត្រាឡើងថ្នាក់ និងអត្រាឆ្លងភូមិសិក្សានៅសាលាបឋមនិងមធ្យមសិក្សា | • បង្កើនអត្រាឡើងថ្នាក់ជាអប្បបរមាពីថ្នាក់ទី១-៦ អោយបាន៩៥% ។<br>• ពិនិត្យនិន្នាការអត្រាឆ្លងភូមិសិក្សា និងផែនការសកម្មភាពសំរាប់កែលំអការឆ្លងភូមិសិក្សាពីថ្នាក់ទី៦-៧។ | • ចាប់ផ្តើមអនុវត្តតេស្តស្តង់ដាអប្បបរមានៅថ្នាក់ទី ២, ៤ និងទី៦<br>• ពិនិត្យឡើងវិញលើការប្រលងនៅថ្នាក់ទី ៩ ដើម្បីពិនិត្យមើលស្តង់ដាជ្រើសរើសសិស្សថ្នាក់ទី ១០ និងការឡើងថ្នាក់។ | • សិក្សាពីផលប៉ះពាល់នៃកម្មវិធី ដែលរួមមានវិសាល-ភាពនៃគុណភាព និងសមធម៌យេនឌ័រ ពីថ្នាក់ទី ១-១២<br>• ពិនិត្យឡើងវិញអំពីផលប៉ះពាល់ផ្តល់ហិរញ្ញប្បទាន ដល់សិស្សក្រីក្រ ដើម្បីកែលំអគោលនយោបាយឆ្លងភូមិសិក្សា និងឡើងថ្នាក់។ |

| | | | |
|---|---|---|---|
| គ-កែលំអបទបញ្ញត្តិស្តីពីអាយុ ៦ឆ្នាំចូលរៀន នៅសាលាបឋមសិក្សា និងការចូលរៀនជាថ្មីនៅក្នុងប្រព័ន្ធសិក្សា ចំពោះសិស្សដែលបានបោះបង់ការសិក្សា | • ដាក់អោយអនុវត្តក្រិត្យ និង គោលការណ៍ណែនាំ ស្តីពីអាយុ៦ឆ្នាំជាវ័យដែលត្រូវចូលរៀននៅសាលាបឋមសិក្សា ដោយផ្សារភ្ជាប់ទៅនឹងការពង្រីកការអប់រំកុមារតូចសំរាប់កុមារអាយុ ៥ឆ្នាំតែប៉ុណ្ណោះ<br><br>• ចេញគោលការណ៍ណែនាំ និងផែនការសកម្មភាពសំរាប់កម្មវិធីចូលរៀនជាថ្មី ពីថ្នាក់ទី៣-៩ សំរាប់សិស្សបោះបង់សាលា។ | • ពិនិត្យឡើងវិញពីការវិវត្តន៍ នៃប្រសិទ្ធភាពគោល-ការណ៍ណែនាំ និង ការបើកថ្នាក់អប់រំកុមារតូច<br><br>• ការពិនិត្យឡើងវិញពីការវិវត្តន៍ នៃកម្មវិធីចូលរៀនជាថ្មីរបស់សិស្សពីថ្នាក់ទី៣-៩ ។ | • សិក្សាពីផលប៉ះពាល់នៃអនុក្រឹត្យថ្មីៗ និងផលពាក់ព័ន្ធចំពោះយុទ្ធសាស្ត្រ ECCD<br><br>• ការសិក្សាផលប៉ះពាល់ស្តីពីកម្មវិធីចូលរៀនជាថ្មី និងផលពាក់ព័ន្ធសំរាប់ការពង្រីក និងការកំណត់មុខសញ្ញា នៅអនាគត។ |
| ឃ-កែលំអ ពង្រីក និងកំនត់គោលដៅកម្មវិធីឧបត្ថម្ភដល់កុមារ ដែលមកពីគ្រួសារក្រីក្រចូលរៀនបឋមសិក្សា មធ្យមសិក្សា និងចូលរៀនក្នុងកម្មវិធីក្រោយមធ្យមសិក្សា | • ផែនការសកម្មភាពសំរាប់ការពង្រីកកម្មវិធី ពីថ្នាក់ទី១-១២ ដោយគិតគូរអំពីនិតិវិធី និងលក្ខណៈវិនិច្ឆ័យនៃការកំណត់មុខសញ្ញាក្រីក្រ<br><br>• កិច្ចព្រមព្រៀងរវាង ក្រសួង អយក ក្រសួងសហវ លើការរួមចំណែករបស់រដ្ឋាភិបាលសំរាប់ថ្នាក់ ទី១-១២<br><br>• ផែនការសកម្មភាព ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភសំរាប់ថ្នាក់ក្រោមមធ្យមសិក្សា វិសាលភាពនៃកម្មវិធី និងនិតិវិធីផ្តល់ហិរញ្ញប្បទាន។ | • ពិនិត្យឡើងវិញពីការវិវត្តន៍ នៃការពង្រីកកម្មវិធីដោយពិនិត្យទៅលើផលប៉ះពាល់នៃកម្មវិធី ចំពោះសិស្សក្រីក្រ និងយេនឌ័រ<br><br>• ពង្រីកកម្មវិធី សំរាប់សិស្សក្រោយមធ្យមសិក្សាដោយផ្សារភ្ជាប់ទៅនឹងលក្ខណៈវិនិច្ឆ័យដែលបានកែសំរួលស្តីពីការជ្រើសរើសសិស្សចូលរៀន<br><br>• ពិនិត្យឡើងវិញពីការវិវត្តន៍ នៃការផ្តល់ប្រាក់លើកទឹកចិត្ត សំរាប់ការបណ្តុះបណ្តាលជំនាញដល់យុវជនរួមទាំង ពិនិត្យមើលផលប៉ះពាល់ នៃការគាំទ្ររបស់រដ្ឋាភិបាល និង មីក្រូឥណទាន។ | • សិក្សាពីផលប៉ះពាល់ លើដំណើរការចុះឈ្មោះចូលរៀនតាមសន្ទស្សន៍នៃភាពក្រីក្រ-យេនឌ័រ<br><br>• កែលំអកម្មវិធីដែលត្រូវដាក់បញ្ចូលក្នុងផែនការ និងកម្មវិធី ពេលខាងមុខ។ |

| | | | |
|---|---|---|---|
| ង- កាត់បន្ថយសាលាបឋមសិក្សាមិនគ្រប់ក៏រិតនៅទូទាំងប្រទេស ដោយគិតទាំងការអភិវឌ្ឍសំភាររូបវ័ន្ត និងវិធានការផ្តល់បុគ្គលិក | • ផែនការអភិវឌ្ឍន៏សំភាររូបវន្តសំរាប់សាលាបឋមសិក្សាមិនគ្រប់ក៏រិត និងយុទ្ធសាស្ត្រផ្តល់បុគ្គលិក<br>• ផែនការសកម្មភាពសំរាប់ចាប់ផ្តើមការបង្រៀនថ្នាក់គួប និងយុទ្ធសាស្ត្រផ្សេងៗទៀត សំរាប់តំបន់ជាប់ព្រំដែន/តំបន់ទើបសមាហរណកម្ម តំបន់ដាច់ស្រយាល និងតំបន់ជនជាតិភាគតិច។ | • ពិនិត្យឡើងវិញពីការវិវត្តន៏ នៃវិសាលភាពកម្មវិធីសំភាររូបវន្ត ដើម្បីឈានទៅលុបបំបាត់សាលាបឋមសិក្សាមិនគ្រប់ក៏រិត<br>• ចាប់ផ្តើមយុទ្ធសាស្ត្រនៃការបណ្តុះបណ្តាលគ្រូបង្រៀនថ្មី ការផ្គត់ផ្គង់ និងការពង្រាយគ្រូបង្រៀននៅតាមសាលារៀនទាំងនេះ ដោយគិតពីការផ្តល់ប្រាក់ឧបត្ថម្ភអោយបានសមរម្យ ។ | • សិក្សាផលប៉ះពាល់ពីប្រសិទ្ធភាពនៃយុទ្ធសាស្ត្រអភិវឌ្ឍសំភាររូបវន្ត និង ដាក់ពង្រាយគ្រូបង្រៀន ។ |
| ច- កែលំអការផ្តល់សេវាសិក្សា ពីថ្នាក់ទី៧-ទី១២ ទាំងនៅតំបន់ខ្វះសេវា និងតំបន់ដែលមានប្រជាជនច្រើនលើសលប់ | • ផែនការអភិវឌ្ឍន៏សំភាររូបវន្តសំរាប់ក៏រិតអប់រំមូលដ្ឋាន ពីថ្នាក់ទី១-៩ ដោយគិតទាំងផលពាក់ព័ន្ធនៃការពង្រាយបុគ្គលិក<br>• អភិវឌ្ឍន៏សំភាររូបវន្តសំរាប់ការពង្រីក ថ្នាក់ទី១០-១២ ដោយគិតទាំងសាលាគំរូ និងការពង្រីកមុខសញ្ញាដទៃទៀត។ | • ពិនិត្យឡើងវិញលើការអភិវឌ្ឍសាលានៅក៏រិតអប់រំមូលដ្ឋាន និងការផ្តល់បុគ្គលិក<br>• ពិនិត្យឡើងវិញពីការវិវត្តន៏ នៃការពង្រីកសំភាររូបវ័ន្តនៅថ្នាក់ទី១០-១២ ដោយពិនិត្យឡើងវិញអំពីលក្ខណៈវិនិច្ឆ័យនៃការកំនត់មុខសញ្ញា។ | • សិក្សាផលប៉ះពាល់ នៃការផ្តល់សំភាររូបវន្តសំរាប់អភិវឌ្ឍន៏ការអប់រំមូលដ្ឋាន និងការអនុវត្តការដាក់ពង្រាយបុគ្គលិក<br>• ពិនិត្យឡើងវិញពីការចូលរៀននៅសាលាគំរូ និងនៅក៏រិតក្រោយមធ្យមសិក្សា ។ |
| ឆ-លើកកំពស់ប្រសិទ្ធភាពនៃភាពជាដៃគូរវាងផ្នែកសាធារណៈ ឯកជន និងសហគមន៏នៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេក-ទេស និងវិជ្ជាជីវៈ (TVET) និងការបណ្តុះបណ្តាលជំនាញដល់យុវជន ។ | • ផែនការសកម្មភាពសំរាប់ពង្រីកផ្នែក TVET និង សេវាបណ្តុះបណ្តាលជំនាញ ដោយគិតទាំងការកំនត់តួនាទីរបស់ផ្នែកសាធារណៈ និងឯកជនអោយបានច្បាស់លាស់ ក្នុងនោះរួមមានការចាប់ផ្តើមបង្កើត មជ្ឈមណ្ឌលសិក្សាសហ-គមន៏ ជាដំណាក់ ៗ | • ពិនិត្យឡើងវិញពីការវិវត្តន៏ នៃកម្មវិធីបណ្តុះបណ្តាលជំនាញ និងកម្មវិធី TVET រួមទាំងការពង្រីកមជ្ឈមណ្ឌលសិក្សាសហគមន៏ និងការរៀបចំអោយមានការផ្លាស់ប្តូរក្រេឌីត | • សិក្សាផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាលជំនាញ និង TVET ដោយគិតទាំងការកែសំរួលយុទ្ធសាស្ត្រ និងលក្ខណៈវិនិច្ឆ័យកំណត់មុខសញ្ញា |

| | | | |
|---|---|---|---|
| | • ផែនការសកម្មភាពសំរាប់ កែទំរង់ហិរញ្ញវត្ថុ និងស្ថាប័ន គិតទាំងការផ្តល់អំណាចច្រើនជាងមុនដល់ គណៈកម្មការជាតិបណ្តុះបណ្តាល (NTB) និង ការពង្រីកមូលនិធិជាតិបណ្តុះ-បណ្តាល (NTF)<br><br>• គោលការណ៏ណែនាំដែលបានឯកភាពគ្នា សំរាប់កែលំអគោលនយោបាយចូលរៀននៅ TVET និងការទទួលស្គាល់គុណភាព (accreditation) គិតទាំងយុទ្ធសាស្រ្តផ្តល់ហិរញ្ញប្បទានដល់សិស្សក្រីក្រ ។ | • ពិនិត្យឡើងវិញការរីកចំរើន នៃការប្រតិបត្តិរបស់ NTB និង NTF ដោយគិតទាំងការកែសំរួល និងការពង្រីកសកម្មភាព<br><br>• ពិនិត្យឡើងវិញយុទ្ធសាស្រ្តផ្តល់ហិរញ្ញប្បទាន ដល់សិស្សក្រីក្រ និងនិរន្តរភាពហិរញ្ញវត្ថុសំរាប់កម្មវិធី ។ | • ការសិក្សាពីផលប៉ះពាល់ស្តីពីតួនាទីនៃ NTB និង NTF ក្នុងការធ្វើអោយប្រសើរឡើងភាពដៃគូរវាង សាធារណៈ និងឯកជន<br><br>ពិនិត្យឡើងវិញពីផលប៉ះពាល់ នៃគំរោងផ្ទេរក្រេឌីតនៅ និងគោលនយោបាយចូលរៀន និង យុទ្ធសាស្រ្តផ្តល់ហិរញ្ញប្បទានដល់សិស្សក្រីក្រ នៅ TVET ។ |
| ជ-លើកកំពស់ប្រសិទ្ធភាពនៃភាពជាដៃគូរវាង សាធារណៈ ឯកជន និងសហគមន៏ ក្នុងការផ្តល់ការអប់រំនៅឧត្តមសិក្សា ដោយគិតទាំងតំបន់មិនទាន់មានសេវា | • ផែនការសកម្មភាព សំរាប់ពង្រឹងការធានាគុណភាពអប់រំ និង ការទទួលស្គាល់គុណភាព រួមទាំង តួនាទីរបស់ ACC ។ | • ពិនិត្យឡើងវិញពីការវិវត្តន៏ នៃផែនការពង្រីកឧត្តមសិក្សា ដោយគិតពីប្រសិទ្ធភាពនៃមូលនិធិដែលបានស្នើឡើងសំរាប់អភិវឌ្ឍន៏ឧត្តមសិក្សា<br><br>• ពិនិត្យឡើងវិញពីការវិវត្តន៏ នៃការធានាគុណភាព និងការទទួលស្គាល់គុណភាព រួមទាំងការរៀបចំចាត់ចែងភាពជាដៃគូ ។ | • សិក្សាពីផលប៉ះពាល់ នៃកម្មវិធីពង្រីកឧត្តមសិក្សា ដោយគិតទាំងលទ្ធភាពនៃការពង្រីកគ្រឹះស្ថានឧត្តមសិក្សាតាមខេត្ត-ក្រុង វិទ្យាល័យសហគមន៏ |

**កំណត់សំគាល់** :ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសកម្មភាពបណ្តុះបណ្តាលជំនាញត្រូវមានការសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ